ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស
អគ្គលេខាធិការដ្ឋាន គជ.ប.ជ.
ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ
លេខ:.................................

# របាយការណ៍

## បូកសរុបលទ្ធផលការងារប្រចាំខែតុលា ឆ្នាំ២០១៩

**ក-អំពីកម្លាំង៖**

សរុបរួមចំនួន៖ ០៧នាក់ (ស្រី ០២នាក់) អវត្តមាន៖ ០០នាក់

**ខ-សកម្មភាព និងលទ្ធផលការងារ**

**-ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៩** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា បានចូលរួមកិច្ចប្រជុំពិភាក្សាត្រៀមរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៩ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ ក្រោមការដឹកនាំសម្របសម្រួលពី **លោកជំទាវ ឧត្តមសេនីយ៍ឯកវេជ្ជ. ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ អញ្ជើញចូលរួមក្នុងកិច្ចប្រជុំនេះមាន ឯកឧត្តម លោកជំទាវ ជាអគ្គលេខាធិការរង ឯកឧត្តម ប្រធាន អនុប្រធានលេខាធិការដ្ឋានរដ្ឋបាល សរុប ប្រធាន អនុប្រធានក្រុមជំនួយកិច្ចការទាំង៦ និងថ្នាក់ដឹកនាំការិយាល័យ មន្ត្រីនៅក្នុងអគ្គលេខាធិការដ្ឋាន គជបជ ជាច្រើនរូប។

**-ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា បានអញ្ជើញចូលរួមកិច្ចប្រជុំត្រៀមរៀបចំផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រជាតិ (២០១៩-២០២៣) ស្តីពីការប្រយុទ្ធប្រឆាំងអំពើរជួញដូរមនុស្ស។ កិច្ចប្រជុំនេះប្រព្រឹត្តិទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ អញ្ជើញចូលរួមក្នុងកិច្ចប្រជុំនេះមាន លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ ជាអគ្គលេខាធិការ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ប្រធាន អនុប្រធានលេខាធិការដ្ឋានរដ្ឋបាល សរុប ប្រធាន អនុប្រធានក្រុមជំនួយកិច្ចការទាំង៦ នៃ គ.ជ.ប.ជ (វត្តមានអង្គប្រជុំសរុបមាន ៣២ នាក់ ស្រី ០៣នាក់)។

**-ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា បានអញ្ជើញចូលរួមជួបពិភាក្សាការងារជាមួយ លោកស្រី Dr. Nette Motus ជានាយិការ (IOM) ប្រចាំតំបន់ ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក រួមនិងសហការី។ អញ្ជើញចូលរួមក្នុងជំនួបនោះដឹកនាំដោយ **ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ លោកជំទាវ អគ្គលេខាធិការ បានផ្តល់អនុសាសន៍ បង្ហាញអំពីរចនាសម្ព័ន្ធ

ដឹកនាំរបស់ គ.ជ.ប.ជ ជូនដល់ប្រតិភូ បន្ថែមពីនេះលោកជំទាវបានបញ្ជាក់អំពីជំហរបើកទូលាយក្នុងកិច្ចសហការជាមួយអង្គការដៃគូរជាតិ និងអន្តរជាតិ និងបានបង្ហាញពីផែនការយុទ្ធសាស្ត្រ២០១៩-២០២៣ ដែលផ្តោតទៅលើយុទ្ធសាស្ត្រទាំងបួនក្នុងកិច្ចការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់រាជរដ្ឋាភិបាល ដែលនឹងត្រូវដាក់បង្ហាញនាពេលឆាប់ៗខាងមុខនេះ ។ លោកជំទាវអគ្គលេខាធិការ ក៏បានបង្ហាញពីក្តីបារម្ភរបស់ថ្នាក់ដឹកនាំទៅលើបញ្ហាពលករចំណាកស្រុក ដែលបច្ចុប្បន្នយើងបានព្យាយាមផ្តល់ភាពស្របច្បាប់ជូនពួកគាត់ហើយតែភាពស្របច្បាប់នោះត្រូវអស់សុពលភាព ស្វែងរកការឯកភាពគ្នារវាងភាគីទាំងពីរ ក្នុងការជួយសម្របសម្រួលទៅដល់ពលករ បន្ថែមពីនេះយើងបានស្នើឲ្យពិនិត្យទៅលើការបញ្ចូលសកម្មភាព ដែលជាផែនការជាតិ ឱ្យបន្សុីគ្នាជាមួយទិសដៅរបស់ GCM និងការអនុវត្តSDG ព្រមទាំងកិច្ចការងារ ប្រមូលតួរលេខពលករដែលត្រូវបានបញ្ជូនត្រឡប់តាមច្រកព្រំដែន កម្ពុជា-ថៃ ជាពិសេស គឺការពិនិត្យសុខភាពស្វែងរក ជំងឺរបេង គ្រុនចាញ់ អេដស៍ និងជំងឺឆ្លងនានា ។ ពាក់ព័ន្ធនឹងកិច្ចសហការគ្នាក្នុងការងារទទួលពលករដែលបញ្ជូនត្រលប់ពីក្រៅប្រទេស លោកជំទាវក៏បានបង្ហាញនូវលទ្ធផលវិជ្ជមានពីសម្រង់ព័ត៌មានពីពលករដែលបញ្ជូនមកមានចំនួនកើនឡើងបើធៀបកាលពី ៦ខែចុងឆ្នាំ២០១៨ និងដើមឆ្នាំ២០១៩។ លោកស្រីនាយិកា តំណាងIOM ក៏បានសន្យាបន្តការសហការសកម្មភាពជាមួយរដ្ឋាភិបាលជាពិសេស គ.ជ.ប.ជ។

**-ថ្ងៃទី០៩ ដល់១១ ខែតុលា ឆ្នាំ២០១៩ លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គជបជ អមដំណើរដោយលោកវរសេនីយ៍ឯក អ៊ិន មាន ប្រធាននៃក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានអញ្ជើញចូលរួមក្នុង កិច្ចប្រជុំនៃក្រុមជំនាញអន្តររដ្ឋាភិបាល ស្តីពីសន្និសីទរបស់រដ្ឋភាគី ប្រព្រឹត្តទៅចាប់ពីថ្ងៃទី ០៩-១១ ខែតុលា ឆ្នាំ២០១៩ នៅទីក្រុងវ៉ែនណា ប្រទេសអូទ្រីស។ កិច្ចប្រជុំនេះរៀបចំឡើងដោយ UNODC ក្នុងសម័យប្រជុំលើកទី១ នៃក្រុមអ្នកជំនាញ អន្តររដ្ឋាភិបាលស្តីពី សន្និសីទរបស់រដ្ឋភាគី ដែលជាកម្មវត្ថុនៃការ ពិគ្រោះយោបល់ ក្រៅផ្លូវការក្នុងចំណោមរដ្ឋ ជាសមាជិកដឹកនាំដោយប្រធានក្រុមអ្នកជំនាញអន្តររដ្ឋាភិបាល ដើម្បីពិនិត្យសម្រេចចុងក្រោយ និងធ្វើសុខដុមនីយកម្ម ទៅលើកម្រង សំនួរស្វ័យវាយតម្លៃ និងរៀបចំ គោលការណែនាំសម្រាប់ធ្វើ ការវាយតម្លៃលើប្រទេស និងផែនការសម្រាប់ បញ្ជីស្តីពីការសង្កេត និងសេចក្តីសង្ខេបនានា ទៅលើយន្តការសម្រាប់ការពិនិត្យឡើងវិញនៃការអនុវត្តអនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មអង្គការឆ្លងដែន និងពិធីសារនានារួមមាន៖ សេចក្តីព្រាង គោលការណ៍ណែនាំ សម្រាប់ធ្វើការត្រួតពិនិត្យប្រទេសនិងប្លង់មេសម្រាប់បញ្ជីនៃការសង្កេតនិងការសង្ខេប កំណត់សម្គាល់ដោយលេខាធិការដ្ឋាន នៅក្នុងសេចក្តីសម្រេចលេខ ៩/១ សន្និសីទ របស់ភាគីនានានៃអនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងអង្គការបានស្នើដល់លេខាធិការដ្ឋានដើម្បីគាំទ្រដល់ដំណើរការនៃការសម្របសម្រួលការងាររបស់ក្រុមអ្នកជំនាញអន្តររដ្ឋាភិបាលដែលរួមមានការរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំ និងប្លង់មេសម្រាប់ការពិចារណា។

**-ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា បានអញ្ជើញចូលជំនួបពិភាក្សាការងារ ជាមួយថ្នាក់ដឹកនាំរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោមអធិបតីភាពលោកជំទាវ ឧត្តមសេនីយ៍ឯកវេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ ជាមួយនឹងប្រតិភូរបស់ ASEAN-ACT ដែលដឹកនាំដោយលោកស្រី Erin Anderson ប្រធានប្រតិភូ របស់ ASEAN-ACT។ ក្នុងជំនួបនេះផងដែរ លោកស្រីប្រធានប្រតិភូ បានថ្លែងបង្ហាញពីយុទ្ធសាស្ត្រ និងវិធីសាស្ត្ររបស់កម្មវិធី ASEAN-ACT និងផែនការសកម្មភាព នៃបេសកកម្មការងាររបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយខាងប្រតិភូក៏បានស្នើសុំនូវកិច្ចសហប្រតិបត្តិការជាមួយ គ.ជ.ប.ជ ក្នុងកិច្ចការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នេះផងដែរ។ អញ្ជើញចូលរួមក្នុងកិច្ចប្រជុំនេះមាន ឯ.ឧ លោកជំទាវ ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ វត្តមាននៃអង្គប្រជុំមាន ០៩នាក់ ស្រី០៥នាក់។

**-ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩** លោកជំទាវ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង ទទួលបន្ទុកការងារក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ និង**លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំស្តីពីការណែនាំកម្មវិធី និងសិក្ខាសាលាពិគ្រោះយោបល់ជាមួយដៃគូរនៃកម្មវិធីអាស៊ាន «អូស្ត្រាលីប្រឆាំងការជួញដូរមនុស្សនៃព្រះរាជាណាចក្រកម្ពុជា» នៅសាលប្រជុំសណ្ឋាគារភ្នំពេញ។ គោលបំណងនៃកិច្ចប្រជុំនេះគឺដើម្បីបង្ហាញពីយុទ្ធសាស្ត្រ និងវិធីសាស្ត្ររបស់កម្មវិធី ASEAN-ACT និងចង់ដឹងនូវអាទិភាពជាយុទ្ធសាស្ត្រកម្រិតខ្ពស់របស់ទីភ្នាក់ងារក្នុងវិស័យយុត្តិធម៌ត្រូវការក្នុងការឆ្លើយតបទៅនឹងការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា។អញ្ជើញចូលរួមក្នុងអង្គប្រជុំនេះមានឯកឧត្តម លោកជំទាវ តំណាងពីក្រសួងសង្គមកិច្ច ស្ថាប័នយុត្តិធម៌ អគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ តំណាងពីស្ថានទូតអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា តំណាងពីអគ្គស្នងការដ្ឋាននគរបាលជាតិ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស អាជ្ញាធរមានសមត្ថកិច្ចជាអ្នកអនុវត្តច្បាប់ និងដៃគូរពាក់ព័ន្ធក្នុងវិស័យយុត្តិធម៌ជាច្រើនរូបទៀត។

**-ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា បានអញ្ជើញដឹកនាំកិច្ចប្រជុំនៃក្រុមការងារពិធិការ និងបដិសណ្ឋារកិច្ច ស្តីពីការចាត់តាំងក្រុមការងាររៀបចំកិច្ចប្រជុំបន្តរវាងប្រទេសបញ្ជូនពលករទាំងបី (កម្ពុជា ឡាវ ភូមា)។

**-ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខណា បានអញ្ជើញចូលរួមកិច្ចប្រជុំរៀបចំដំណើរការកិច្ចប្រជុំពិគ្រោះយោបល់បច្ចេកទេសលើកទី២ក្នុងចំណោមប្រទេសបញ្ជូនទាំង ៣ កម្ពុជា ឡាវ ភូមា (CLM) ស្តីពីតួនាទីនៃប្រទេសបញ្ជូនសម្រាប់ពង្រឹងការការពារជនចំណាកស្រុកដោយប្រថុយប្រថាន នឹងការងារដោយបង្ខំ និងការជួញដូរមនុស្ស ដែលនឹងប្រព្រឹត្តិឡើងនៅសណ្ឋាគារ សុខាអង្គរខេត្តសៀមរាប

ប្រទេសកម្ពុជា ក្រោមការចូលរួមជាអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ នៅថ្ងៃទី៣០-៣១ ខែតុលា ឆ្នាំ២០១៩ខាងមុខ។ កិច្ចប្រជុំនេះប្រព្រឹត្តិទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ អញ្ជើញចូលរួមក្នុងកិច្ចប្រជុំនេះមាន **លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ . ប៉ុណ្ណ សំខាន់** ជាអគ្គលេខាធិការ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ប្រធាន អនុប្រធានលេខាធិការដ្ឋានរដ្ឋបាល សរុប ប្រធាន អនុប្រធានក្រុមជំនួយកិច្ចការទាំង៦ នៃ គ.ជ.ប.ជ និង ឯ.ឧ លោកជំទាវ លោក លោកស្រីតំណាងមកពី ក្រសួង ស្ថាប័ន ពាក់ព័ន្ធជាច្រើនរូប ដែលវត្តមានអង្គប្រជុំសរុបមាន ២៦នាក់ ស្រី០៦នាក់។

**-ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា បានអញ្ជើញជួបពិភាក្សាជាមួយ លោក គង់ វីឡា នាយប្រតិបត្តិ Cambodia ACTs ដើម្បីផ្តល់ជាអនុសាសន៍លើកិច្ចការងារបន្តរបស់ Cambodia Acts ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសកិច្ចសហការជាមួយ គ.ជ.ប.ជ។

**-ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា បានអញ្ជើញចូលរួមក្នុងពិធីចុះអនុស្សរណៈយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរវាង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមាន **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ ជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ.ជ.ប.ជ ជាមួយនឹងអង្គការការីតាសស្វីស ដែលមាន **លោក ម៉ាក គ្លូក្លឿ** (Marc Gloekler) នាយកប្រចាំប្រទេសកម្ពុជា រួមនិងសហការី។ មានវត្តមានចូលរួមជាគណៈអធិបតី និងសាក្សីមាន ឯកឧត្តម លោកជំទាវ ជារដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អញ្ជើញជាតំណាងអន្តរក្រសួងស្ថាប័នជាសមាជិករបស់ គ.ជ.ប.ជ មានក្រសួងសង្គមកិច្ច ក្រសួងការបរទេស ក្រសួងអប់រំយុវជន និងកីឡា ពីក្រសួងកិច្ចការនារី ក្រសួងទេសចរណ៍ លោកជំទាវអគ្គលេខាធិការ និងអគ្គលេខាធិការរង គ.ជ.ប.ជ តំណាងពីអគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងមន្ត្រីជាច្រើនរូបទៀត។

**-ថ្ងៃទី ២២ ខែតុលា ឆ្នាំ២០១៩** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សា ត្រៀមឆ្លើយតបទៅនឹងកម្រងសំនួរស្វ័យវាយតម្លៃរបស់ UNODC ទៅលើការងារប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស ដែលមានការចូលរួមពីរបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អគ្គលេខាធិការរងទទួលបន្ទុកនិង ប្រធានក្រុមជំនួយកិច្ចការទាំង៦ ក្រោមការដឹកនាំរបស់ **លោកជំទាវ ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅបន្ទប់ប្រជុំរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

**-ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩** លោកជំទាវ ឧត្តមសេនីយ៍ទោ វ៉ន សិរីលក្ខិណា និងក្រុមការងារ នៃក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ បានអញ្ជើញចូលរួម និងមានតួនាទីជាក្រុមការងារពិធីការក្នុងកិច្ចប្រជុំផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រជាតិ (២០១៩-២០២៣) ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃអគារT។ អញ្ជើញចូលរួមក្នុងកម្មវិធីនេះមាន ឯកឧត្តម លោកជំទាវ តំណាងក្រសួង ស្ថាប័នរដ្ឋ ឯកអគ្គរាជទូត ប្រចាំព្រះរាជាណាចក្រកម្ពុជា រាជធានី - ខេត្ត អង្គការដៃគូអភិវឌ្ឍ ឯកជន ពាក់ព័ន្ធជាច្រើនរូប។

**-ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩** លោកវរសេនីយ៍ឯក អ៊ិន មាន ក្រោមការដឹកនាំដោយឯកឧត្តម ឧត្តមសេនីយ៍ឯក ស៊ុន រ៉ូ បានអញ្ជើញចូលរួមធ្វើបទសម្ភាសន៍ ទាក់ទងនឹងការបាត់ខ្លួនពលករខ្មែរដែលចាញ់បោកមិត្តភក្រ ធ្វើការល្បួងអោយរៀបការជាមួយជនជាតិចិន ហើយទៅរស់នៅប្រទេសចិន។ នារីរងគ្រោះនោះបានរងការធ្វើបាបពីសំណាក់ជនជាតិចិន បន្ទាប់មកក៏ធ្វើការលែងលះ និងរៀបការជាថ្មីម្តងទៀតជាមួយអ្នកផ្សេង ហើយក៏បានបាត់ដំណឹងរហូត។ ក្រោយពីបានធ្វើបទសំភាសន៍រួចមក ក្រុមគ្រួសារជនរងគ្រោះ ត្រូវបានណែនាំអោយធ្វើការដាក់ពាក្យបណ្តឹង ទៅកាន់នាយកដ្ឋាន ប្រឆាំងការជួញដូរ និងការពារអនីតិជន នៃអគ្គស្នងការនគរបាលជាតិ។

**-ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៩** លោកជំទាវ ឧត្តមសេនីយ៍ទោ វ៉ន សិរីលក្ខិណា លោកស្រីវរសេនីយ៍ត្រី ថោង សុវត្ថិ និងក្រុមការងារ បានទទួលធ្វើបដិសណ្ឋារកិច្ចគណៈប្រតិភូដែលអញ្ជើញមកពីប្រទេសឡាវ និងភូមា ដើម្បីចូលរួមកិច្ចប្រជុំប្រទេសបញ្ជូនពលករបីប្រទេស កម្ពុជា ឡាវ ភូមា (CLM ) ស្តីពី តួនាទីនៃប្រទេសបញ្ជូនសម្រាប់ពង្រឹងការការពារជនចំណាកស្រុកដោយប្រថុយប្រថាននឹងការងារដោយបង្ខំ និង ការជួញដូរមនុស្ស ដែលនឹងប្រព្រឹត្តិឡើងនៅសណ្ឋាគារ សុខាល័យអង្គរខេត្តសៀមរាប (និងជូនដំណើរនិវត្តន៍របស់ប្រតិភូទាំងពីរប្រទេស នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៩)។

**-ថ្ងៃទី៣០ ដល់ ៣១ ខែតុលា ឆ្នាំ២០១៩** លោកជំទាវ ឧត្តមសេនីយ៍ទោ វ៉ន សិរីលក្ខិណា និង លោកស្រីវរសេនីយ៍ត្រី ថោង សុវត្ថិ បានចូលរួម និងក្នុងតួនាទីជាក្រុមពិធីការក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើកទី ២ កម្រិតថ្នាក់ដឹកនាំបច្ចេកទេស នៃប្រទេសបញ្ជូនទាំងបី កម្ពុជា ឡាវ ភូមា (CLM) នៅខេត្តសៀមរាប ស្តីពី "តួនាទីប្រទេសបញ្ជូនដើម្បីពង្រឹងកិច្ចការពារទេសន្តរប្រវេសន៍" នៃប្រទេសបញ្ជូនសម្រាប់ពង្រឹងការការពារជនចំណាកស្រុកដោយប្រថុយប្រថាននឹងការងារដោយបង្ខំ និងការជួញដូរមនុស្ស ដើម្បីប្រមូលធាតុផ្សំល្អៗបញ្ចូលគ្នាដែលប្រទេសទាំងបី មានកាតព្វកិច្ច ការពារសិទ្ធិ និងផលប្រយោជន៍ របស់ពលករ ប្រទេសរៀងៗខ្លួន ទាំងអ្នក ស្របច្បាប់ និងអ្នកមិនស្របច្បាប់។ កិច្ចប្រជុំបានទទួលកិត្តិយសដ៏ខ្ពង់ខ្ពស់ប្រកាសបើកដោយ **សម្តេចក្រឡាហោម ស ខេង**

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មការជាតិប្រយុទ្ធប្រឆាំអំពើរជួញដូរមនុស្ស និងដឹកនាំបន្តដោយ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ នេះគឺជាការប្រមូលមតិគ្នារវាងប្រទេសទាំងបីដើម្បី ប្រមូលធាតុចូលល្អៗ ការពារ ពលករ ខ្លួនឯងផង និងដើម្បីជួយថៃឲ្យមានដំណោះ ស្រាយជុំវិញបញ្ហាពលករទេសន្តរប្រវេសន៍ផង ដែលបច្ចុប្បន្ន ថៃកំពុងរងនូវការរិះគន់ពីអន្តរជាតិជុំវិញការប្រើពលករមិនស្របច្បាប់។ អញ្ជើញចូលរួមក្នុងកិច្ចប្រជុំនេះមាន លោកជំទាវ ឯកឧត្តម លោកជំទាវ តំណាងក្រសួងស្ថាប័ន អស់លោក លោកស្រីតំណាង អង្គការដៃគូអភិវឌ្ឍន៍ជាច្រើនរូបទៀត។

**ឃ-ទិសដៅបន្ត**

- បញ្ចូលព័ត៌មានអង្គការដៃគូអភិវឌ្ឍន៍ទៅលើរបាយការណ៍ និងកែតម្រូវនូវចំនុចខ្វះខាតមួយចំនួន
- ទទួលភារកិច្ច បែងចែកសម្រាប់ការងារ ទិវាជាតិថ្ងៃ១២ធ្នូ

ថ្ងៃ ខែ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១៩

**ប្រធាន**

**ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**

ចម្លងជូន៖

-លេខាធិការដ្ឋានរដ្ឋបាលសរុប

-លោកជំទាវអគ្គលេខាធិការរងទទួលបន្ទុក

"ដើម្បីជូនជ្រាប"

ឯកសារកាលប្បវត្តិ-